ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ..............................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ថ្ងៃព្រហស្បតិ៍ ១១រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រឡងប្រជែងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងរ៉ែ និង ថាមពល សម្រាប់ឆ្នាំ២០១៨

ក្រសួងរ៉ែ និង ថាមពលសូមជូនដំណឹងដល់មន្ត្រីរាជការ និស្សិត និង សាធារណជនឱ្យបានជ្រាបថា សម្រាប់ឆ្នាំ២០១៨នេះ ក្រសួងនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ក្របខណ្ឌថ្មី (**ប្រភេទ «ក»**) ចំនួន១១កន្លែង ឱ្យចូលបម្រើការងារ នៅតាមអង្គភាពនានាចំណុះក្រសួងរ៉ែ និង ថាមពល ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។

## ១. មុខជំនាញជ្រើសរើស

- រ៉ែ ឬ ភូគព្ភសាស្ត្រ
- សេដ្ឋកិច្ច គណនេយ្យ ធនាគារ និង ហិរញ្ញវត្ថុ
- នីតិសាស្ត្រ ឬ រដ្ឋបាលសាធារណៈ

## ២. អង្គភាពដែលត្រូវជ្រើសរើសចូលបម្រើការងារ

*២.១ នៅទីស្តីការក្រសួង៖* ត្រូវការជ្រើសរើសចំនួន ០៥កន្លែង។

*២.២ នៅមន្ទីររ៉ែ និង ថាមពលខេត្ត៖* ត្រូវការជ្រើសរើសចំនួន ០៦កន្លែង តាមអង្គភាពដូចខាងក្រោម៖

| ល.រ. | អង្គភាពត្រូវការជ្រើសរើស | ចំនួន |
|---|---|---|
| ១ | មន្ទីររ៉ែ និង ថាមពលខេត្តកំពង់ស្ពឺ | ០១ កន្លែង |
| ២ | មន្ទីររ៉ែ និង ថាមពលខេត្តកំពត | ០១ កន្លែង |
| ៣ | មន្ទីររ៉ែ និង ថាមពលខេត្តកោះកុង | ០១ កន្លែង |
| ៤ | មន្ទីររ៉ែ និង ថាមពលខេត្តបាត់ដំបង | ០១ កន្លែង |
| ៥ | មន្ទីររ៉ែ និង ថាមពលខេត្តព្រះសីហនុ | ០១ កន្លែង |
| ៦ | មន្ទីររ៉ែ និង ថាមពលខេត្តប៉ៃលិន | ០១ កន្លែង |



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

## ៣. លក្ខខណ្ឌជ្រើសរើស

*បេក្ខជនជានិស្សិត ឬ សាធារណជន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖*

- ត្រូវមានសញ្ជាតិខ្មែរ
- បេក្ខជន ដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬ សញ្ញាបត្រសមមូល ត្រូវមានអាយុមិនឱ្យលើសពី ៣៥ឆ្នាំ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨)
- បេក្ខជន ដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬ សញ្ញាបត្រសមមូលត្រូវមានអាយុមិនឱ្យលើសពី៤០ឆ្នាំ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨)
- បេក្ខជន ដែលមានសញ្ញាបត្របណ្ឌិត ឬ សញ្ញាបត្រសមមូលត្រូវបានលើកលែងលក្ខខណ្ឌអាយុ។

*បេក្ខជនមន្ត្រីរាជការ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖*

- ត្រូវបានលើកលែងចំពោះលក្ខខណ្ឌអាយុ
- មានសញ្ញាបត្រសមស្របតាមមុខជំនាញជ្រើសរើសក្នុងសេចក្ដីជូនដំណឹង
- ត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែង និង អនុញ្ញាតឱ្យផ្ទេរក្របខណ្ឌនៅពេលប្រឡងជាប់ជាស្ថាពរ ពីប្រធានក្រសួង-ស្ថាប័នសាមី។

## ៤. វិញ្ញាសាប្រឡង

វិញ្ញាសាប្រឡងមានពីរប្រភេទ គឺវិញ្ញាសាសរសេរ និង វិញ្ញាសាផ្ទាល់មាត់៖

*៤.១ វិញ្ញាសាសរសេររួមមាន៖*

- វិញ្ញាសាវប្បធម៌ទូទៅ ( រយៈពេល ១:៣០ នាទី ) មេគុណនឹង១
- វិញ្ញាសាភាសាអង់គ្លេសទូទៅ ( រយៈពេល ១:៣០ នាទី) មេគុណនឹង១
- វិញ្ញាសាជំនាញបច្ចេកទេស ( រយៈពេល ៣:០០ នាទី) មេគុណនឹង២

*៤.២ វិញ្ញាសាផ្ទាល់មាត់៖* សម្រាប់បេក្ខជនដែលប្រលងជាប់វិញ្ញាសាសរសេរ។

## ៥. កាលបរិច្ឆេទប្រឡង

- សម្រាប់វិញ្ញាសាសរសេរនឹងប្រព្រឹត្តទៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៨
- សម្រាប់វិញ្ញាសាផ្ទាល់មាត់នឹងមានជូនដំណឹងនៅពេលក្រោយ។

## ៦. មណ្ឌលប្រឡង

- សម្រាប់វិញ្ញាសាសរសេរ នឹងមានជូនដំណឹងនៅពេលក្រោយ
- សម្រាប់វិញ្ញាសាផ្ទាល់មាត់ នឹងប្រព្រឹត្តទៅនៅទីស្ដីការក្រសួងរ៉ែ និង ថាមពល។

## ៧. ទីកន្លែង និង កាលបរិច្ឆេទលក់ពាក្យ ទទួលពាក្យ និងឈប់ទទួលពាក្យប្រឡង

*៧.១ ទីកន្លែង និង កាលបរិច្ឆេទលក់ពាក្យ និងទទួលពាក្យ៖* ការលក់ និង ទទួលពាក្យប្រឡងប្រព្រឹត្តទៅចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅរៀងរាល់ថ្ងៃធ្វើការ ពេលព្រឹកពីម៉ោង៧:៣០នាទី ដល់ម៉ោង១១:៣០នាទី និងពេលរសៀល ពីម៉ោង១៤:៣០នាទី ដល់ម៉ោង១៧:០០ល្ងាច នៅនាយកដ្ឋានបុគ្គលិក (ជាន់ទី២) ក្រសួងរ៉ែ និងថាមពល អគារលេខ ៧៩,៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

*៧.២ កាលបរិច្ឆេទឈប់លក់ពាក្យ និង ទទួលពាក្យ៖* ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០១៨។

## ៨. សំណុំលិខិតដែលបេក្ខជនត្រូវបំពេញ ក្នុងការដាក់ពាក្យប្រឡង

១. ពាក្យសុំចុះឈ្មោះប្រឡង ចំនួន ០១ច្បាប់

២. សេចក្ដីចម្លងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និង សញ្ញាបត្រជំនាញ(បញ្ជាក់ផ្លូវការ) ចំនួន ០១ច្បាប់

៣. ជីវប្រវត្តិសង្ខេប មានបិទរូបថត ( ៤ X ៦ ) ចំនួន ០១ច្បាប់

៤. សលាកបត្រឯកត្តជន ចំនួន ០២ច្បាប់

៥. រូបថតថ្មី (៤ X ៦) ចំនួន ០២សន្លឹក
៦. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង ចំនួន ០២ច្បាប់
៧. កិច្ចសន្យាការងារ ចំនួន ០១ច្បាប់
៨. សេចក្តីចម្លងសំបុត្រកំណើត ឬ អត្តសញ្ញាណបណ្ណថតចម្លងមានបញ្ជាក់ផ្លូវការ ចំនួន ០១ច្បាប់
៩. លិខិតថ្កោលទោស និង លិខិតបញ្ជាក់សុខភាព(ក្រោយប្រកាសលទ្ធផលជាប់ជាស្ថាពរ)ចំនួន ០១ច្បាប់

*សេចក្តីបញ្ជាក់៖*

- **បេក្ខជនជាជនពិការ និង ស្ត្រី** ដែលមានសមត្ថភាពសមស្រប នឹងត្រូវបានផ្តល់អាទិភាព។
- **បេក្ខជនជាជនពិការ** ត្រូវមានលិខិតបញ្ជាក់ពិការភាព។
- **ព័ត៌មានលម្អិត** សូមមកធ្វើទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិករៀងរាល់ម៉ោងធ្វើការ ឬ តាមរយៈទូរស័ព្ទលេខ៖ *០១២ ៣២១ ០០០/០១២ ៥៥ ៣៧ ០១។*

អាស្រ័យហេតុនេះ សូមនិស្សិត និង សាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន។

**រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល**:
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-រដ្ឋបាលខេត្ត ដែលពាក់ព័ន្ធ
-គ្រប់អង្គភាពចំណុះទីស្តីការក្រសួងរ៉ែ និង ថាមពល
-គ្រប់មន្ទីររ៉ែ និង ថាមពលរាជធានី ខេត្ត
-ឯកសារ កាលប្បវត្តិ